ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
*******

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ : ២៣
ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០០
សាលដីកា
លេខ : ៩៤
ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០០០

**នាមនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០០០ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ ៖

១. ឯកឧត្តម ឃឹម ប៉ុណ្ណ ជាប្រធាន
២. លោក ឈឹម ស៊ីផល ចៅក្រម
៣. លោក ប្រាក់ គីមសាន ចៅក្រម
៤. លោក វៀល មួន ចៅក្រម
៥. លោក យស់ សួខឿន ចៅក្រម-របាយការណ៍

ក្រឡាបញ្ជី
លោក សាន សុផាត

តំណាងមហាអយ្យការ
ឯកឧត្តម ជួន ស៊ុនឡេង អគ្គព្រះរាជអាជ្ញាស្តីទី

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ១៩៦ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៩របស់សាលាឧទ្ធរណ៍និងសំណុំរឿងព្រហ្មទណ្ឌលេខ២៣ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០០ របស់តុលាការកំពូល ។

<u>ពីបទ</u> : ធ្វើអោយខូចខាតទ្រព្យសម្បត្តិអ្នកដទៃ និងសមគំនិត ប្រព្រឹត្តិនៅខេត្តកំពង់ចាមកាលពីថ្ងៃទី២៥ ខែឧសភាឆ្នាំ១៩៩៣ បទល្មើសព្រហ្មទណ្ឌដែលមាន ចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥២ នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល ចុះថ្ងៃទី១០-៩-១៩៩២ ។

១. ជនជាប់ចោទឈ្មោះលី ស៊ាងវ៉ាង (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ កើតនៅឃុំសួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម របររកស៊ីធ្វើយោធា

ទីលំនៅសព្វថ្ងៃ ភូមិស្ទួង ឃុំស្ទួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ ឪពុកឈ្មោះលី ស៊ាងប៉េង (រស់) ម្ដាយឈ្មោះ ប៉ុក ណារីន (រស់ ) នៅលីវ ។ ក្រៅឃុំ ។

-មានមេធាវី លោក តែ ចំណាន

២_ ជនជាប់ចោទឈ្មោះលី ស៊ាងវ៉ុង ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើយោធា ទីលំនៅសព្វថ្ងៃភូមិស្ទួង ឃុំស្ទួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ ឪពុកឈ្មោះលី ស៊ាងប៉េង (រ) ម្ដាយឈ្មោះប៉ុក ណារីន (រ) នៅលីវ ។ ក្រៅឃុំ ។

៣_ ជនជាប់ចោទឈ្មោះលី ស៊ាងម៉េង ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ របររកស៊ីកម្មករ ទីលំនៅសព្វថ្ងៃភូមិសាឡង់២ ក្រុមហ៊ុនចំការកៅស៊ូមេមត់ ខេត្តកំពង់ចាម ។ ឪពុកឈ្មោះលី ស៊ាងប៉េង (រ) ម្ដាយឈ្មោះប៉ុក ណារីន (រ) ប្រពន្ធឈ្មោះថាន ចន្ទ មានកូន១នាក់ ។ នៅក្រៅឃុំ ។

៤_ ជនជាប់ចោទឈ្មោះលី ស៊ាងប៉េង ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ របររកស៊ីចាស់ជរា ទីលំនៅសព្វថ្ងៃនៅភូមិស្ទួង ឃុំស្ទួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ ឪពុកឈ្មោះអ៊ាត ងន់ (ស) ម្ដាយឈ្មោះឌី អុល (រ) ប្រពន្ធឈ្មោះប៉ុក ណារីន (រ) មានកូន៩នាក់ ។ នៅក្រៅឃុំ ។

_ ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះទាវ ម៉េងហួរ ( ជាចុងបណ្ដឹងសាទុក្ខ ) ភេទប្រុស អាយុ៤៧ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ដូរ ទីលំនៅសព្វថ្ងៃភូមិស្ទួង លិច ឃុំស្ទួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ មេធាវីគ្មាន ។

_ តាមពាក្យបណ្ដឹងរបស់ឈ្មោះទាវ ម៉េងហួរ ប្ដឹងពីជនជាប់ចោទ៤នាក់ ខាងលើ ពីបទៈធ្វើឱ្យខូចខាតទ្រព្យសម្បត្តិរបស់ខ្លួនដោយចេតនាកាលពីថ្ងៃទី២២_៥_១៩៩៣ ។

_ បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការខេត្ត កំពង់ចាមបានសំរេច ៖ ចោទលើជនជាប់ចោទឈ្មោះលី ស៊ាងវ៉ុង _ លី ស៊ាងម៉េង និង លី ស៊ាងវ៉ាង ពីបទៈ ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃដោយចេតនា តាមមាត្រា៥២ច្បាប់ ព្រហ្មទណ្ឌ អន្តរកាល ។

_ បានឃើញសាលក្រមព្រហ្មទណ្ឌ លេខ៣១ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៦ របស់តុលាការខេត្តកំពង់ចាម ដែលបានសំរេច ៖

១- ផ្តន្ទាទោសឈ្មោះលី ស៊ាងង៉េង -លី ស៊ាងវ៉ុង និង លី ស៊ាងវ៉ាង ដាក់ពន្ធនាគារកំណត់១ឆ្នាំតែទោសនេះត្រូវព្យួររយៈពេលសាកល្បង៥ឆ្នាំគិតពីថ្ងៃសាលក្រមចូលជាស្ថាពរ ពីបទៈ ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃដោយចេតនាប្រព្រឹត្តិនៅភូមិស្ទួងលិច ឃុំស្ទួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម កាលពីថ្ងៃទី២២-៥-១៩៩៣តាមមាត្រា៥២ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២- ឱ្យឈ្មោះលី ស៊ាងង៉េង - លី ស៊ាងវ៉ាង - លី ស៊ាងវ៉ុង រួមគ្នាសងថ្លៃខូចខាតផ្ទះចំនួន៥តម្លឹងមាសគីឡូនិងជំងឺចិត្ត១លានរៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីពីឈ្មោះទាវ ម៉េងហួរ នៅពេលសាលក្រមចូលជាស្ថាពរ ការប្តឹងទាមទារលើសពីនេះលើកចោល ។ ក្នុងករណីអ្នកទាំង៣មិនព្រមសងគ្រប់ចំនួនទេ តុលាការនឹងចាប់បង្ខំដាក់គុកដល់រូបកាយ ដើម្បីទារប្រាក់គ្រប់ចំនួន តាមមាត្រា៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំរូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៣- ឱ្យលី ស៊ាងប៉េង រួចផុតពីបណ្តឹងអាជ្ញាចាប់ពីថ្ងៃនេះតទៅ ។

៤- សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីកំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ២២ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៦របស់ឈ្មោះលី ស៊ាងវ៉ាង និងបណ្តឹងឧទ្ធរណ៍លេខ២៨ចុះថ្ងៃទី១០-៨-១៩៩៦របស់ឈ្មោះទាវ-ម៉េងហួរ ដែលប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ៣១ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៦របស់តុលាការខេត្តកពង់ចាម លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ចោទបន្ថែមលើឈ្មោះលី ស៊ាងប៉េង ពីបទៈសមគំនិត បំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃតាមមាត្រា៦៩ និង៥២ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានឃើញសាលដីកាកំបាំងមុខព្រហ្មទណ្ឌលេខ១៨២ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ដែលបានសំរេច ៖

១- ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១០-៨-៩៦របស់ឈ្មោះទាវ ម៉េងហួរ ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២. ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៣_៧_៩៦របស់ឈ្មោះលី_ស៊ាងវ៉ាង ទុកជាទ្រឹមត្រូចតាមទំរង់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣. តម្កល់សាលក្រមលេខ៣១(គ)ចុះថ្ងៃទី១៤_៦_៩៦របស់តុលាការខេត្តកំពង់ចាម ទុកជាបានការ លើកលែងចំណុចទី៣ ត្រូវបដិសេធចោលហើយសំរេចជាថ្មី ផ្តន្ទាទោសជនជាប់ចោទឈ្មោះលី ស៊ាងប៉េង ដាក់ពន្ធនាគារកំណត់១ឆ្នាំ តែព្យួរយៈពេលសាកល្បង៥ឆ្នាំ គិតពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ ពីបទៈ សមគំនិតធ្វើឱ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃ ដោយចេតនាតាមមាត្រា៥២_៦៩និង៧០ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

និងចំណុចទី២ ត្រូវកែប្រែថាៈបង្គាប់ឱ្យឈ្មោះលី ស៊ាងប៉េង_លី ស៊ាងង៉េង លី ស៊ាងវ៉ុង និងលី ស៊ាងវ៉ាង រួមគ្នាសងថ្លៃខូចខាតផ្ទះចំនួន៧តំឡឹងនិងជំងឺចិត្ត១លានរៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ចំណុចផ្សេងទៀតរក្សាទុកនៅដដែល ។

៤. សាលដីកានេះ ជំនុំជំរះនិងប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទសំរេចបើកផ្លូវប្តឹងទាស់និងសាទុក្ខក្នុងកំណត់ច្បាប់។

- បានឃើញបណ្តឹងទាស់លេខ១៤(ស្ទួន)ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ របស់ឈ្មោះលី ស៊ាងង៉េង_លី ស៊ាងវ៉ុង_លី ស៊ាងប៉េង និងលី ស៊ាងវ៉ាង ដែលប្តឹងតវ៉ាពីសាលដីកាកំបាំងមុខព្រហ្មទណ្ឌ១៨២ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៩៦ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៩ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ដែលបានសំរេច ៖

១. ទទួលបណ្តឹងទាស់ចុះថ្ងៃទី១០_៦_៩៩របស់ឈ្មោះលី ស៊ាងង៉េង លី ស៊ាងវ៉ុង_លី ស៊ាងប៉េងនិងលី ស៊ាងវ៉ាង ទុកជាត្រឹមត្រូវតាមទំរង់តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២. តម្កល់សាលដីកាកំបាំងមុខលេខ១៨២ ចុះថ្ងៃទី២៦_៨_៩៩របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣. សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះលី ស៊ាងង៉េង_លី ស៊ាងវ៉ុង_លី ស៊ាងវ៉ាង និង ដើមបណ្តឹងរដ្ឋប្បវេណី

កំបាំងមុខជនជាប់ចោទឈ្មោះលី ស៊ាងប៉េង តែចាត់ទុកជាចំពោះមុខ បើកផ្លូវប្តឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ១០៣ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៩របស់ឈ្មោះលី ស៊ាងវ៉ាង ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ១៩៦ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៩របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណា ចុះថ្ងៃទី២១-៥-២០០០ របស់ឈ្មោះលី ស៊ាងវ៉ាង (ជាម្ចាស់បណ្តឹងសាទុក្ខ)ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានឃើញសារណាតប ចុះថ្ងៃទី១២-៦-២០០០របស់ឈ្មោះទាវ ម៉េងហួរ (ជាចុងបណ្តឹងសាទុក្ខ) ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថាៈ ការរុះរើផ្ទះរបស់ប្រជាជនអាចរុះរើបាន អាស្រ័យលើសាលក្រមតុលាការ រដ្ឋអំនាចមូលដ្ឋានគ្មានសិទ្ធិរុះរើទេ ណាមួយលោក ទាវ ម៉េងហួរ គ្មានការព្រមព្រៀងឱ្យរុះរើនេះឡើយ ។ ដូច្នេះសូមតុលាការសំរេចតាមច្បាប់ ។

-បានស្តាប់ចម្លើយអះអាង របស់ឈ្មោះ លី ស៊ាងវ៉ាង(ជាម្ចាស់បណ្តឹងសាទុក្ខ)នៅពេលជំនុំជំរះថាៈ សាលាឧទ្ធរណ៍សំរេចកំបាំងមុខ ខ្ញុំបាទដោយអយុត្តិធម៌ ខ្ញុំបាទមិនសុខចិត្ត សូមតុលាការ មេត្តាជួយរកយុត្តិធម៌ឱ្យខ្ញុំបាទផង ។

- បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះទាវ ម៉េងហួរ (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថាៈ សាលាឧទ្ធរណ៍សំរេច២លើក ពុំមែនមួយលើកទេ ការសំរេចនេះជាការសំរេចត្រឹមត្រូវ សូមតុលាការកំពូលសំរេចតាមនេះ ។

- បានស្តាប់សេចក្តីសន្និដ្ឋានការពារលោកតែ ចំណាន មេធាវី ការពារឱ្យឈ្មោះលី ស៊ាងវ៉ាង នៅពេលជំនុំជំរះថាៈ ការរុះរើនេះមានការព្រមព្រៀងពីរដ្ឋអំណាចជនជាប់ចោទគ្មានកំហុស ម្យ៉ាងការវាយតម្លៃផ្ទះរុះរើនេះ ជាការវាយតម្លៃខុសព្រោះការរុះរើនៅឆ្នាំ១៩៩៣ បែរជាមកវាយតម្លៃក្នុងឆ្នាំ១៩៩៦ទៅវិញ សូមតុលាការមេត្តាជ្រាប ។

- បានស្ដាប់សេចក្ដីសន្និដ្ឋានបន្ថែមនាពេលសវនាការរបស់តំណាងមហាអយ្យ-ការ អមតុលាការកំពូលថា សូមរក្សាការសន្និដ្ឋានខាងលើទុកនៅដដែល ។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងសេចក្ដីសន្និដ្ឋាន របស់មេធាវីជនជាប់ចោទ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

តុលាការកំពូល

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ៩១ ចុះថ្ងៃទី២២-៩-៩៩របស់ជនជាប់ចោទឈ្មោះលី ស៊ាងវ៉ាង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្ដីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្ដី ។

- យល់ឃើញថា ការលើកឡើងរបស់ឈ្មោះលី ស៊ាងវ៉ាង ហៅទីមគង់ក្នុងសារណាចុះថ្ងៃទី២១-៥-២០០០ថាដើមបណ្ដឹងរដ្ឋប្បវេណីលោកទាវ ម៉េងហួរ បានសុំកន្ទុយដីក្រោយផ្ទះខ្លួនរស់នៅមួយរយៈតែក្រោយមកមិនព្រមរុះផ្ទះចាស់ចេញពីដីខ្លួន ព្រមទាំងបានដាក់បង្កប់គ្រាប់បែកដៃចំនួន០២គ្រាប់និងគ្រាប់អាកាចំនួន១បង់នោះគឺជាការពុំត្រឹមត្រូវឡើយពីព្រោះថាៈ

+ ពុំមានភស្ដុតាងណាមួយបញ្ជាក់ថាលោកទាវ ម៉េងហួរ បានបង្កប់គ្រាប់បែក និងមានគ្រាប់អាកាចំនួន១បង់ឡើយ ម្យ៉ាងទៀតសូម្បីតែសមត្ថកិច្ចនៅមូលដ្ឋានក៏ពុំបានចោទប្រកាន់លើឈ្មោះទាវ ម៉េងហួរ ដែរ ។

+ មានភស្ដុតាងគ្រប់គ្រាន់បញ្ជាក់ថាជនជាប់ចោទទាំងអស់ពិតជាបានប្រព្រឹត្តអំពើបំផ្លិចបំផ្លាញគេហដ្ឋានរបស់ដើមបណ្ដឹងរដ្ឋប្បវេណីប្រាកដមែន ។

- យល់ឃើញថា ការដែលមេធាវីជនជាប់ចោទអះអាងថាៈការរុះរើផ្ទះនេះដោយមានការឯកភាពពីរដ្ឋអំណាចមូលដ្ឋាននោះជាការពុំត្រឹមត្រូវទេ ពីព្រោះរដ្ឋអំណាចមូលដ្ឋានដែលលោកមេធាវីអះអាងនោះពុំមានសមត្ថកិច្ចអនុញ្ញាតិឱ្យអ្នកណាមួយរុះរើឬធ្វើឱ្យខូចខាតទ្រព្យសម្បត្តិជនណាមួយឡើយ ចំពោះសំណងរដ្ឋប្បវេណីតុលាការកំពូលពុំអាចពិចារណាឡើយ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ១៩៦ ចុះថ្ងៃទី៣០_៧_៩៩របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់និងគតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យ សេចក្តីចំពោះមុខជនជាប់ចោទនិងដើមបណ្តឹងរដ្ឋប្បវេណី

១_ ទទួលបណ្តឹងសាទុក្ខលេខ៩១ ចុះថ្ងៃទី២២_៩_៩៩របស់ជនជាប់ចោទឈ្មោះ លី ស៊ាងវ៉ាង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

២_ តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១៩៦ ចុះថ្ងៃទី៣០_៧_៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣_ សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០០ ៕